**កោះសន្តិភាព** ឆ្នាំទី៤២ លេខ៦៧០២ ថ្ងៃពុធ ទី១៥ ខែកក្កដា ឆ្នាំ២០០៩




បាតុកររាប់ពាន់នាក់ចោមរោមពេញរង្វង់មូលអ្នកលឿង (រូបថត ចក្រី)

# ផ្ទុះបាតុកម្មតវ៉ា "បញ្ហាថ្លៃភ្លើង_សំរាម" កក្រើកតំបន់អ្នកលឿង

ខេត្តព្រៃវែង : បាតុកម្មតវ៉ា ដោយការក្តៅក្រហាយ បានកើតមានឡើងនៅទីប្រជុំជនអ្នកលឿង ត្រើយខាងកើត ក្នុងឃុំព្រែកខ្សាយ "ក" ស្រុកពាមរក៍ ហើយការិយាល័យអ្នកម៉ៅការភ្លើងអគ្គិសនី បានរងការគប់នឹងដុំថ្ម ដំបង និងវត្ថុផ្សេងៗទៀត បណ្តាលឱ្យមានការខូចខាតយ៉ាងដំណំ។ ព្រឹត្តិការណ៍នេះបានក្លាយជាចលាចលអនាធិបតេយ្យពេញបន្ទុកមួយនៅវេលា រសៀលថ្ងៃទី១៤ កក្កដា ដែលក្រុមប្រជាពលរដ្ឋមានស្រីមានប្រុសក្មេងចាស់ប្រមាណជាង១.០០០នាក់ បាននាំគ្នាតវ៉ាពីបញ្ហាតំលៃភ្លើងអគ្គិសនី និងបញ្ហាផ្សេងៗទៀតទាក់ទិននឹងការតបណ្តាញចរន្តថ្មី ដែលតភ្ជាប់ពីប្រទេសវៀតណាម ។

តាមសេចក្តីរាយការណ៍របស់អ្នកឆ្លើយឆ្លងព័ត៌មានប្រចាំនៅតំបន់អ្នកលឿងជំហានដំបូងបានឱ្យដឹងថាក្រុមប្រជាពលរដ្ឋបានលើកគ្នាទៅឈរត្រៀបត្រានៅមុខការិយាល័យអ្នកម៉ៅការភ្លើងអគ្គិសនីដែលគេស្គាល់គ្រប់គ្នាគឺលោកជំទាវប៊ុន លីវ ជាភរិយារបស់លោកឧកញ៉ានៅ សុខា ។




ក្រុមបាតុករដែលប្រមូលផ្តុំគ្នាពេញរង្វង់មូលតំបន់អ្នកលឿង (រូបថត ចក្រី)

ការធ្វើបាតុកម្មរបស់ប្រជាពលរដ្ឋនៅតំបន់អ្នកលឿងនេះ អាចនិយាយបានថា ជាការផ្ទុះឡើងព្រមៗគ្នាតែម្តងប្រៀបដូចជាសភាពការណ៏ទុំជោរ នៃបញ្ហាដែលតម្រូវឱ្យមានការដោះស្រាយ ចំពោះការគាបសង្កត់យ៉ាងខ្លាំងក្លាដោយសារការរកស៊ីផ្តាច់មុខរបស់អ្នកម៉ៅការភ្លើងនេះ ។ ក្រុមប្រជាពលរដ្ឋបានចោទប្រកាន់ជាច្រើនចំណុចក្នុងនោះ ចំណុចទី១-តំលៃកុងទ័រ នាំចូលថ្លៃតែ៥ដុល្លារទេ ដែលមានបិទស្លាក ISO 9001 តែពេលលក់ចេញបកស្លាកចេញ បិទតែមប្រើវត្តភ្នំ និងបានលក់ក្នុងតំលៃ៣០ដុល្លារ ។ ចំណុចទី២-ប្រជាពលរដ្ឋ បានអះអាងថា ពីពេលមុនប្រើភ្លើងអស់តែ១០គីឡូវ៉ាត់ តែពេលនេះឡើងដល់ទៅ២០គីឡូវ៉ាត់ ហើយបើមានការតវ៉ា គឺទាមទារឱ្យដូរកុងទ័រភ្លាម តែបើមិនតវ៉ាគឺទុកដដែល ។ ចំណុចទី៣-គឺបញ្ហាសំរាម ផ្ទះតូចតាចយកកន្លះខែ១៥០០រៀល ដូច្នេះ១ខែយក៣០០០រៀល បើផ្ទះធំយក៥០០០រៀលទៅ១ម៉ឺនរៀល ឬយកដល់ទៅ៥ម៉ឺនរៀលក៏មាន ។ បញ្ហាសំរាមដដែល ប្រជាពលរដ្ឋដែលនៅឆ្ងាយពីទីប្រជុំជនរកតែសំរាមធ្វើជីមិនបាន ក៏តំរូវឱ្យបង់ថ្លៃសេវាសំរាមដែរ បើមិនព្រមបង់ផ្តាច់ភ្លើងចោលលែងឱ្យប្រើ ។

បញ្ហាមួយទៀត ចំពោះការចាក់សាបនៅផ្សារចាស់អ្នកលឿងដែលទទួលការអនុគ្រោះពីសម្តេចតេជោនោះ ថាចាក់ឱ្យមានអនាម័យ ផ្ទុយទៅវិញបែរជាលក់ឱ្យអាជីវករ បើមិនទិញមិនឱ្យលក់ទេ ។ ទាក់ទិននឹងភាសីចូលផ្សារវិញ បើចូលផ្សារតាមច្រកណា ត្រូវចេញតាមច្រកនោះ បើចេញខុសផ្លូវយកលុយទៀត ។

ប្រការទាំងនេះហើយ ដែលបង្កជាភ្លើងកំហឹងឱ្យឆាបឆេះឡើងដូចទឹកបាក់ទំនប់ ។




ស្ថានីយប្រេងដែលជាទីតាំងការិយាល័យត្រូវបានរងការគប់បំផ្លាញ (រូបថត ចក្រី)

តំលៃភ្លើងអគ្គិសនីបច្ចុប្បន្ននៅតំបន់អ្នកលឿង គឺ១គីឡូវ៉ាត់ថ្លៃ១.៧០០រៀល ហើយក្រុមប្រជាពលរដ្ឋ បានតវ៉ាឱ្យចុះតំលៃភ្លាមៗត្រឹម៧០០រៀល តែការតវ៉ានេះត្រូវបានក្រុមអ្នកម៉ៅការភ្លើងអគ្គិសនី និយាយថាមិនអាចចុះបានភ្លាមៗទេ ។ មន្ត្រីឃុំព្រែកខ្សាយ"ក" បានឱ្យដឹងថា ចរន្តភ្លើងដែលបានតភ្ជាប់ពីប្រទេសវៀតណាមតាមច្រកបន្ទាយចក្រីក្នុងស្រុកព្រះស្តេច គឺបានតំរូវឱ្យយកតំលៃ១គីឡូវ៉ាត់១.៧០០រៀល ហើយរយៈពេល២ខែម្តងត្រូវចុះតំលៃ១០០រៀល ដែលការចុះនេះបន្តរហូតដល់នៅសល់៧០០រៀល លែងចុះទៀតហើយ ។

អាស្រ័យដោយមានកំហឹងតាំងពីយូរមកហើយ ក្រុមប្រជាពលរដ្ឋបានចោទថា អ្នកម៉ៅការបានហុតឈាមប្រជាពលរដ្ឋពីតំលៃភ្លើងកន្លងមកវាល្មមគ្រប់គ្រាន់ហើយ ពួកគេគួរតែចុះថ្លៃព្រោះតំលៃភ្លើងដែលទិញពីវៀតណាម ១គីឡូវ៉ាត់តែ

៦០០រៀលទេ។ ក្រុមប្រជាពលរដ្ឋបានចោទទៀតថា អ្នកប្រមូលលុយថ្លៃប្រើចរន្តភ្លើង គេតែងបង្កឧបសគ្គសំរាប់អ្នកបង់លុយរាយហើយមានបញ្ហាជាច្រើនទៀត ។



ប្រជាពលរដ្ឋជាបាតុករមានចំនួនរាប់ពាន់នាក់មានក្មេងមានចាស់ (រូបថត ចក្រី)

គេមិនអាចរកការបំភ្លឺណាមួយភ្លាមៗបានទេពីលោកឧកញ៉ានៅ សុខា ឬក៏ភរិយារបស់លោក ដែលជាប្រធានម៉ៅការភ្លើងនៅតំបន់អ្នកលឿងនោះ។ ក្រុមប្រជាពលរដ្ឋដែលមានកំហឹង បានឈរឡោមព័ទ្ធ និងគប់ទៅលើការិយាល័យ ទោះបីត្រូវមន្ត្រីសមត្ថកិច្ចហាមឃាត់យ៉ាងណាក្តីក៏មិនមានការគោរពតាមនោះទេ។

ក្នុងអំឡុងនៃវេលាកើតហេតុនេះ ចរន្តភ្លើងអគ្គិសនីនៅទីប្រជុំជនអ្នកលឿងទាំងមូលត្រូវដាច់ងងឹតទាំងអស់ នៅភ្លឺតែកន្លែងដែលគេមានម៉ាស៊ីនភ្លើងឯកជនផ្ទាល់ខ្លួនប៉ុណ្ណោះ ។ ហេតុការណ៏ដែលមិនធ្លាប់កើតមាននេះដែរ ក៏មិនបានរំខានដល់ដំណើរការកំពង់ចំលងដែលនៅក្បែរនោះទេ គ្រាន់តែមានការកកស្ទះ ហើយក្រុមសមត្ថកិច្ចបានព្យាយាមធ្វើចរាចរណ៏ ។ តាមសេចក្តីរាយការណ៏ថា ពេលកើតហេតុផ្ទុះកំហឹងទប់មិនឈ្នះពីសំណាក់ប្រជាពលរដ្ឋនេះ វត្តមានប្រធានម៉ៅការភ្លើង មិនបានស្ថិតនៅក្នុងការិយាល័យទេ រាប់ទាំងក្រុមបុគ្គលិក ឬកម្មករគឺបាននាំគ្នាគេចខ្លួនអស់ហើយ ។




មន្ត្រីប៉ូលិសឈរលើឡានទឹកនិយាយតាមមេក្រូសុំឱ្យបាតុកររកដំណោះស្រាយ (រូបថត ចក្រី)

នៅវេលាល្ងាចថ្ងៃដដែល ក៏មានការបារម្ភដែរថា អាចនឹងមានឧប្បត្តិហេតុធ្ងន់ធ្ងរប្រសិនបើមិនរំសាយកំហឹងក្រុមប្រជាពលរដ្ឋបាន ព្រោះមន្ត្រីស្រុកមន្ត្រីសមត្ថកិច្ចប៉ូលិស ប៉េអឹមហាមឃាត់លែងស្តាប់ទៅហើយ ។

មន្ត្រីខ្លះខ្លាចថា អាចមានក្រុមជនឆក់ឱកាសបង្កជាបាតុភាពធ្ងន់ធ្ងរជាងនេះ ដូច្នេះហើយទើបនៅកន្លែងធ្វើបាតុកម្មមានរថយន្តពន្លត់អគ្គិភ័យ២គ្រឿង និងរថយន្តសង្គ្រោះ១គ្រឿង បានបញ្ឈរក្បែរនោះជាការត្រៀមទប់ស្កាត់រាល់បាតុភាពដែលអាចកើតមានជាយថាហេតុ ។

ក្នុងព្រឹត្តិការណ៍នេះតាមសេចក្តីរាយការណ៍ថា មានក្មេងប្រុសម្នាក់បានរងរបួស ខណៈពេលមានការគប់ជញ្ជាំទៅលើការិយាល័យរបស់អ្នកម៉ៅការភ្លើង។ ក្រោយពីបាតុភាពអូសបន្លាយ គេសង្កេតឃើញមន្ត្រីនានារាប់ទាំងស្នងការស្នងការរងប៉ូលិសខេត្ត បានចុះទៅធ្វើការសំរបសំរួលក្រុមប្រជាពលរដ្ឋដើម្បីបញ្ឈប់ការធ្វើបាតុកម្មនេះ ហើយរង់ចាំការដោះស្រាយពីប្រមុខរាជរដ្ឋាភិបាល ។ បន្ទាប់ពីមានការព្យាយាមសំរបសំរួល ក្រុមប្រជាពលរដ្ឋប្រមាណ៧0%បានរំសាយ។ នេះបើយោងតាមសេចក្តីរាយការណ៍ត្រឹមម៉ោងជាង៦ល្ងាច ក្នុងថ្ងៃដដែល ។